00633785

លេខ/No: D427/1/25

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៧៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាឆ្លើយតប ទៅនឹងសេចក្ដីសង្ខេបរួមទៅលើបណ្ដឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក អៀង សារី៖**

អាង ឧត្តម

Michael G. KARNAVAS

ឯកសារទទួល

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 01 / 2011

ម៉ោង (Time/Heure): 15:50

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គីមសាន ប្រធាន

ចៅក្រម ន៍យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមដាក់ការឆ្លើយតបនេះទៅនឹង សេចក្តីសង្កតរួម របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ("ចម្លើយតប")[1]។ ការឆ្លើយតបនេះ នឹងលើកឡើងនូវបញ្ហា នានា ដែលមាននៅក្នុងចម្លើយតប ដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍របស់ លោក អៀង សារី[2] ។ ការចោទ ប្រកាន់ខាងអង្គហេតុដែលមាននៅក្នុងចម្លើយតបនឹងមិនលើកយកមកដោះស្រាយឡើយ។

## I. សេចក្តីសង្ខេបនៃចម្លើយតប

១. ដើម្បីបណ្តឹងរដ្ឋប្បវេណីអះអាងដូចតទៅនេះ៖

ក) លោក អៀង សារី ភ័ន្តច្រលំក្នុងការអះអាងថាឧក្រិដ្ឋកម្មអន្តរជាតិដែលគាត់ត្រូវបានគេចោទ ប្រកាន់មិនអាចអនុវត្តបាននៅចំពោះមុខ អវតក ពីព្រោះ៖

i. ច្បាប់សិទ្ធិសញ្ញាអន្តរជាតិអាចអនុវត្តបាននៅ អវតក

ii. ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាពិសេស jus cogens គឺអាចអនុវត្តបាននៅចំពោះមុខ អវតក

iii. លោក អៀង សារី ភ័ន្តច្រលំក្នុងការអះអាងថា ករណីលើកលែងក្រោមមាត្រា ១៥(២) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ICCPR") គឺមិនអាចអនុវត្តបាននៅ ចំពោះមុខ អវតក

---

[1] រឿងក្តី អៀង សារី សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អ.ប.ជ១៤៦) សេចក្តីសង្កេតរួមរបស់សហមេធាវី ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំដោះស្រាយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/3/8 ERN: 00626531-00626650 ។

[2] *ករណីអៀង សារី* សំណុំរឿងលេខ០០២/១៩-០៩-២០០៧-អវតក/កសចស(អ.ប.ជ៧៥) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារD427/1/6 ERN: 00617486-00617631 (បណ្តឹង ឧទ្ធរណ៍)។

00633787



ខ) គោលការណ៍នីត្យានុកូលភាពគឺមិនត្រូវបានរំលោភឡើយ ដោយអនុវត្តច្បាប់អន្តរជាតិ ដោយសារ អង្គជំនុំជម្រះ សាលាដំបូងក្នុងរឿងក្តី ឌុច បានអនុវត្តច្បាប់អន្តរជាតិ និងដោយសារវាមិនរំលោភលើគោលការណ៍នីត្យានុកូលភាព ដើម្បីប្រែក្លាយដោយអនុវត្តប្រតិសកម្មនូវច្បាប់អន្តរជាតិមកជាច្បាប់ជាតិព្រោះវាគឺជាបញ្ហានីតិវិធី។

គ) លោក អៀង សារី ភ័ន្តច្រលំក្នុងការអះអាងថា មិនបានដឹងអំពីឧក្រិដ្ឋកម្មអន្តរជាតិដែលគាត់ត្រូវបានគេចោទប្រកាន់ ព្រោះដោយសារចរិតលក្ខណៈឃោរឃៅនៃឧក្រិដ្ឋកម្មនេះ និងឋានៈជាមេដឹកនាំរបស់គាត់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

## II. **សង្ខេបនៃការឆ្លើយតប**

២. មេធាវីការពារក្តីនឹងបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រលំ៖

ក) ដោយសំអាងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច*

ខ) ដោយសន្និដ្ឋានថា អនុសញ្ញាអន្តរជាតិអាចអនុវត្តបានដោយផ្ទាល់នៅ អវតក ។ ដើមបណ្តឹងរដ្ឋប្បវេណី ភ័ន្តច្រលំរវាងសិទ្ធិនិង កាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិ ទៅនឹង សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលជាមួយនឹងរដ្ឋ ហើយនិងយល់ច្រលំអំពីអំណះអំណាងរបស់មេធាវីការពារក្តីទាក់ទងទៅនឹងការបន្តមរតករបស់រដ្ឋចំពោះអនុសញ្ញា

គ) ដោយសន្និដ្ឋានថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចយកមកអនុវត្តបានដោយផ្ទាល់នៅ អវតក

ឃ) ដោយសន្និដ្ឋានថា គោលការណ៍នីត្យានុកូលភាពមិនរារាំងការចោទប្រកាន់ឧក្រិដ្ឋកម្មអន្តរជាតិ និង

ង) ការវិភាគរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើការអាចប្រមើលមើលឃើញជាមុន និងការផ្សព្វផ្សាយដែលអាចស្វែងរកបាន

## III. **ការឆ្លើយតប**

### ក. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រលំដោយសំអាងទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច*

៣. តាមរយៈចម្លើយតបទាំងមូល មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្រង់យកជាសំអាងដោយទទួលស្គាល់នូវសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច*[3]។ ដើមបណ្តឹងរដ្ឋប្បវេណីបានថែមទាំងចោទមេធាវីការពារក្តី ថាភ័ន្តច្រលំអង្គច្បាប់ "ដោយមិនបានយកចិត្តទុកដាក់ពិចារណាលើយុត្តិសាស្ត្ររបស់អវតក"[4]។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* មិនចងភ្ជាប់ កសចស ឬ អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ទេ។ បើសិនជាសាលក្រមនោះមានតម្លៃ ក៏តម្លៃរបស់វាមានកម្រិតដែរ ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* មិនត្រូវបានគេស្នើអោយពិចារណាថា តើច្បាប់អនុសញ្ញា ឬទំនៀមទម្លាប់អន្តរជាតិ អាចអនុវត្តបានដោយផ្ទាល់នៅ កម្ពុជា ដែរឬអត់[5]។ ការតតាំងរបស់មេធាវីការពារក្តីរបស់ *ឌុច* ទៅលើភាពអនុវត្តបានរបស់ច្បាប់ និងទម្រង់នៃការទទួលខុសត្រូវ គឺមានកម្រិតបំផុត។ ជាពិសេស ការជំនុំជម្រះក្តី *ឌុច* គឺគ្រាន់តែជាកែប្រែដែលអូសបន្លាយលើសវនាការដែលមានការឆ្លើយសារភាពប៉ុណ្ណោះ[6]។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច*

---

[3] *សូមមើល* ចម្លើយតប កថាខណ្ឌ 7, 15, 16, 19, 21, 23, 26, 27, 28, 29, 30 ។

[4] ដូចជើងទំព័រខាងលើ ទំព័រ ១២។

[5] ដូចដែលអង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា "វាជាបញ្ហាចងភ្ជាប់ដល់តុលាការដែលមាននីតិវិធីជាច្រើនកំពុងរង់ចាំការសម្រេចដែលសេចក្តីសេចក្តីទៅលើករណីមួយ អំពីបញ្ហាអង្គច្បាប់ នឹងណែនាំដល់តុលាការនាអនាគតសម្រាប់រឿងក្តីស្រដៀងគ្នា ដែលគ្មានកាលៈទេសៈថ្មី ឬអំណះអំណាងថ្មី ត្រូវបានលើកឡើង" *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ២) សេចក្តីសម្រេចលើសំណើសុំរបស់ អៀង សារី សុំដាក់សេចក្តីសន្និដ្ឋានស្តីពីការអនុវត្តនូវទ្រឹស្តីស្តីពីសហឧក្រិដ្ឋកម្មរួម ទៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាបញ្ជូន កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ទៅជំនុំជម្រះ ចុះថ្ងៃទី ៥ ធ្នូ ២០០៨ ឯកសារលេខ D99/3/19, ERN: 00226067-00226070 កថាខណ្ឌ ១៤ (គូសបញ្ជាក់បន្ថែម)។

[6] "ការជំនុំជម្រះក្តី ឌុច អាចបង្ហាញនូវលក្ខណៈទោលក្នុងប្រវត្តិសាស្ត្រនៃ អវតក ដែលក្នុងនោះគាត់គឺជាជនជាប់ចោទតែម្នាក់ប៉ុណ្ណោះមកដល់សព្វថ្ងៃនេះ ដែលបានសារភាពទទួលស្គាល់នូវការចោទប្រកាន់អង្គហេតុដ៏ធំសម្បើមប្រឆាំងនឹគាត់។ ថ្វីបើ ឌុច បានស្នើសុំអោយគាត់រួចផុតពីបទចោទនៅក្នុងសប្តាហ៍ចុងក្រោយការជំនុំជម្រះក្តីរបស់គាត់ គាត់បានសហការយ៉ាងធំធេងជាមួយអង្គជំនុំជម្រះពេញមួយរយៈកាលនៃកិច្ចដំណើរការនីតិវិធី ហើយ រហូតមកដល់ចំណុចនេះ បានសម្តែងនូវភាពស្តាយក្រោយ និងបាននឹងកំពុងទទួលយកការដាក់ទោសទណ្ឌ។ ជាលទ្ធផល សិទ្ធិនៅក្នុងដំណើរការនីតិវិធីដែលធានាអោយមានសច្ចាធារណ៍នៃនិរទោស (ឬដែលមើលទៅ

បានត្រឹមតែប្រើប្រាស់បទល្មើស ដែលបានចែងនៅក្នុងច្បាប់បង្កើត អវតក ប៉ុណ្ណោះ ដោយមិនបានពិចារណាថា តើការធ្វើនេះនឹងរំលោភគោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់កម្ពុជាដែរឬអត់ឡើយ។ មេធាវីការពារក្តី ត្រូវបានហាមឃាត់មិនអាចធ្វើអន្តរាគមនៅក្នុងសំណុំរឿង ០០១ ដើម្បីបកស្រាយបញ្ហានៃច្បាប់ដែលត្រូវយកមកអនុវត្ត ឧទាហរណ៍ដូចជា ការយកមកប្រើប្រាស់នូវសហឧក្រិដ្ឋកម្មរួម ដែលធ្វើនេះគឺដើម្បីការពារផលប្រយោជន៍នៅក្នុងសំណុំរឿង ០០២[7] ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* មិនបានធ្វើការវិភាគដោយឯករាជ្យទៅលើភាពអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម និងការវិភាគការអនុវត្តសហឧក្រិដ្ឋកម្មរួមក្នុងសាលក្រមនោះមានតែពីរកថាខណ្ឌប៉ុណ្ណោះ[8]។ ហេតុដូច្នេះ ការអនុវត្តនូវច្បាប់អន្តរជាតិមានក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* ដាច់ខាតមិនត្រូវបានគេយកមកពិចារណាថាវាមានតម្លៃជាយុត្តិសាស្ត្រឡើយ។

**ខ. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រឡំ ដោយសន្និដ្ឋានថា អនុសញ្ញាអន្តរជាតិអាចអនុវត្តបានដោយផ្ទាល់នៅ អវតក**

**១. ដើមបណ្តឹងរដ្ឋប្បវេណី ភ័ន្តច្រឡំរវាងសិទ្ធិនិង កាតព្វកិច្ចរបស់រដ្ឋក្រោមច្បាប់អន្តរជាតិ ទៅនឹង សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលជាមួយនឹងរដ្ឋ**

---

ទំនងជារាំងការផ្ទេរបន្ទុកនៃការបង្ហាញភស្តុតាង ពីអយ្យការមកចុងចោទ) មិនចោទជាបញ្ហាឡើយ។ ជាឧទាហរណ៍ មេធាវីការពារក្តី មិនបានតតាំងនឹងចរិតលក្ខណៈនៃភស្តុតាងដែលគេយកមកប្រឆាំងនឹងឌុច (ដែលភាគច្រើនជាចងក្រងឯកសារ ហេតុដូច្នេះហើយបើកចំហរមានការខូចខាត ដោយសាររយៈកាល៣០ឆ្នាំ ចាប់តាំងពីសម័យកាលកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់)។ លើសពីនេះទៅទៀត បញ្ហាទាក់ទងនឹងការបកប្រែត្រូវបានដោះស្រាយភ្លាមៗ ដោយមិនគិតអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាពនៃការបកប្រែទាំងផ្ទាល់មាត់ និងសរសេរនៅ អវតក ឡើយ" ។ អត្ថបទរបស់ Michelle Staggs Kelsall et al., *Lessons Learned from the "Duch" Trial: A Comprehensive Review of the First Case Before the Extraordinary Chambers in the Courts of Cambodia*, KRT TRIAL MONITORING GROUP ចេញផ្សាយខែធ្នូ ឆ្នាំ ២០០៩ ទំព័រ ៦។

[7] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០២) សេចក្តីសម្រេចលើសំណើសុំរបស់ អៀង សារី ស្នើសុំដាក់សេចក្តីសន្និដ្ឋានស្តីការអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួមនៅក្នុង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូន កាំង ហ្គេកអ៊ាវទៅជំនុំជម្រះ ចុះថ្ងៃទី ៥ ធ្នូ ២០០៨ ឯកសារលេខ D99/3/19, ERN: 00226067-00226070។

[8] *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អសជ សាលក្រម ចុះថ្ងៃទី ២៦ កក្កដា ២០១០ ឯកសារលេខ E188, ERN: 00226067-00226070 កថាខណ្ឌ ៥១១-៥១២។

៤. ដើម្បីបណ្តឹងរដ្ឋប្បវេណី អះអាងថា អនុសញ្ញាទីក្រុងហ្សឺណែវ និងអនុសញ្ញាប្រល័យពូជសាសន៍អាចអនុវត្តបាននៅកម្ពុជានៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយហេតុថាកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងនេះនៅមុនឆ្នាំ ១៩៧៥[9]។ ទោះថា កម្ពុជាត្រូវបានចងភ្ជាប់ដោយអនុសញ្ញាអន្តរជាតិឬអត់នោះ គឺជាបញ្ហាទីទៃពីគ្នាពីរឿងដែលថា តើអនុសញ្ញាទាំងនេះអាចអនុវត្តបានដើម្បីបង្កើតបានជាការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលនៅក្នុងតុលាការជាតិ។ បើសិនជាកម្ពុជាក្លាយជាភាគីនៃអនុសញ្ញាមួយ កម្ពុជាអាចបំពេញកាតព្វកិច្ចក្នុងនាមជារដ្ឋមួយ។ រឿងនេះគឺជារឿងដោយឡែកពីគ្នាទាំងស្រុងពីរឿងដែលថា តើអនុសញ្ញានោះអាចត្រូវបានគេយកមកអនុវត្តដោយផ្ទាល់ដើម្បីកំណត់ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបុគ្គលនានានៅក្នុងរដ្ឋមួយបានដែរឬអត់។ ដើមបណ្តឹងរដ្ឋប្បវេណី ទំនងជាមិនទទួលស្គាល់ភាពខុសប្លែកគ្នានេះសោះ[10]។ កម្ពុជាមិនត្រូវបានគេចោទប្រកាន់ពីបទថាមិនបានគោរពទៅតាមកាតព្វកិច្ចខ្លួននៅក្នុងសន្ធិសញ្ញាឡើយ។

៥. ទោះថា ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល អាចប្រើប្រាស់បានដោយតុលាការកម្ពុជា ឬក៏អត់នោះ វាពឹងផ្អែកទៅលើថា តើកម្ពុជាពិចារណាថា អនុសញ្ញាអន្តរជាតិនានានឹងក្លាយជាស្វ័យប្រវត្តិជាផ្នែកមួយនៃច្បាប់កម្ពុជាដែរឬអត់ ឬ ថាតើ កម្ពុជា ពិចារណាថា អនុសញ្ញាទាំងនោះត្រូវតែជាដំបូងប្រែក្លាយទៅច្បាប់ជាតិជាមុនសិន ដើម្បីអោយវាមានអានុភាព (ជាពិសេស ថាតើ កម្ពុជា ប្រកាន់យកប្រព័ន្ធឯកនិយម(monist) ឬ ទ្វិកនិយម(dualist)ចំពោះច្បាប់អន្តរជាតិ)[11] ។ បើសិនជាកម្ពុជា

---

[9] ចម្លើយតប កថាខណ្ឌ ៨-១២។

[10] ជាឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អនុសញ្ញាប្រល័យពូជសាសន៍ និងទីក្រុងហ្សែណែវ បានចូលជាធរមាននៅក្នុងអំឡុងពេលកម្ពុជាប្រជាធិតេយ្យ ហើយបានថ្លែងទាំងមានកំហុសថា "ថ្វីបើពួកគេបានដឹងយ៉ាងពេញលេញនូវស្ថានភាពនេះ ជនជាប់ចោទ អះអាងថា បញ្ហាដែលថារដ្ឋាភិបាលកម្ពុជាមិនបានយោងទៅលើអនុសញ្ញាអន្តរជាតិដែលរៀបរាប់ខាងលើ នៅក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ គឺជាភស្តុតាងបង្ហាញថា គេមិនបានពិចារណាថាគេត្រូវបានចងភ្ជាប់ដោយអនុសញ្ញាទាំងនោះឡើយ។" ចម្លើយតប កថាខណ្ឌ ១០។ មេធាវីការពារក្តី បានអះអាងថា រដ្ឋាភិបាលកម្ពុជាមិនបានអនុម័តនូវច្បាប់សម្រាប់អនុវត្ត ដែលនឹងកំណត់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះការរំលោភបំពានលើអនុសញ្ញាទាំងនោះនៅក្នុងអំឡុងឆ្នាំ ១៩៧៩។ បញ្ហានេះមិនមែនគ្រាន់តែថា រដ្ឋាភិបាលមិនបាន "យោង" ទៅលើអនុសញ្ញាទាំងនោះនៅក្នុងអំឡុងរយៈពេលនេះទេ។

[11] *សូមមើល* បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១១-១១៤ សម្រាប់ការពិភាក្សាទៅលើភាពខុសគ្នារវាងរដ្ឋប្រកាន់យកប្រព័ន្ធឯកនិយម ឬ ប្រព័ន្ធទ្វិកនិយម។

ប្រកាន់យកប្រព័ន្ធឯកនិយម (monist) អង្គបុរេជំនុំជម្រះ ដាច់ខាតត្រូវតែសម្រេចថា តើអនុសញ្ញា ក) មានចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដែរឬទេ និង ខ) មានលក្ខណៈស្វ័យអនុវត្តដែរឬទេ។ បើសិន កម្ពុជា ប្រកាន់យកប្រព័ន្ធទ្វិកនិយម(dualist) អង្គបុរេជំនុំជម្រះ ដាច់ខាតត្រូវតែសម្រេចថា តើកម្ពុជា បានអនុម័តនូវច្បាប់សម្រាប់អនុវត្ត ដើម្បីប្រែក្លាយនូវអនុសញ្ញានោះ អោយក្លាយទៅជាច្បាប់ជាតិ ហើយថាតើ ច្បាប់ជាតិនេះមានចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដែរឬទេ។

៦. ប្រទេសកម្ពុជាប្រកាន់យកប្រព័ន្ធទ្វិកនិយមក្នុងការអនុវត្តច្បាប់អន្តរជាតិ[12] ។ ក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ មិនមានច្បាប់ដែលចែងពីការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចំពោះការរំលោភបំពានអនុសញ្ញាប្រល័យពូជសាសន៍ ឬអនុសញ្ញាទីក្រុងហ្សឺណែវឡើយ ។ បើទោះបីជាប្រទេសកម្ពុជាប្រកាន់យកប្រព័ន្ធឯកនិយម ក៏អនុសញ្ញាប្រល័យពូជសាសន៍ ឬអនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រូវបានអនុវត្តដោយឯងៗដែរ[13] ហើយក៏ប្រហែលជាមិនអាចអនុវត្តដោយផ្ទាល់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលដែរ ។ ចំណុចនេះ បង្ហាញយ៉ាងច្បាស់ពីបទបញ្ញត្តិទាំងនេះដែលតម្រូវឲ្យរដ្ឋអនុវត្តច្បាប់ដែលចែងពីការទទួលខុសត្រូវជាលក្ខណៈបុគ្គល[14] ។ ដូច្នេះ ការទទួលខុសត្រូវជាលក្ខណៈបុគ្គល មិនអាចពឹងផ្អែកតែទៅលើបញ្ហាថាតើប្រទេសកម្ពុជា គឺជាភាគីនៃអនុសញ្ញាប្រល័យពូជសាសន៍ ឬអនុសញ្ញាទីក្រុងហ្សឺណែវ ឬអត់នោះទេ។

---

[12] សូមមើលបណ្តឹងសារទុក្ខ, កថាខណ្ឌទី១១១។

[13] សូមមើលករណី William A. Schabas, នៅទីបញ្ចប់តុលាការជាតិចាប់ផ្តើមកាត់ទោសអំពើប្រល័យពូជសាសន៍,...

[14] មាត្រា ៥ នៃអនុសញ្ញាប្រល័យពូជសាសន៍ចែងថា "រដ្ឋជាភាគីហត្ថលេខីត្រូវធ្វើការអនុម័ត ដោយស្របជាមួយនឹងរដ្ឋធម្មនុញ្ញរៀងខ្លួនៗ នូវច្បាប់ដែលចាំបាច់ ដើម្បីផ្តល់អានុភាពដល់បញ្ញត្តិនៃអនុសញ្ញាបច្ចុប្បន្ននេះ ហើយជាពិសេស ត្រូវចែងអំពីទោសទណ្ឌអោយមានប្រសិទ្ធិភាពដាក់ទៅលើជនទាំងឡាយ ដែលមានទោសកំហុសចំពោះអំពើប្រល័យពូជសាសន៍ ឬអំពើទាំងឡាយដែលមានរៀបរាប់នៅក្នុងមាត្រា៣។" មាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី ១ មាត្រា ៥០ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី ២ មាត្រា ១២៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី ៣ និងមាត្រា ១៤៦ នៃ អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ ដែលមាត្រាមួយៗចែងថា "ភាគីហត្ថលេខីត្រូវធ្វើការអនុម័តនូវច្បាប់ដែលចាំបាច់ ដើម្បីផ្តល់ប្រសិទ្ធិភាពដល់ទោសទណ្ឌព្រហ្មទណ្ឌដាក់ទៅលើបុគ្គលនានាដែលបានប្រព្រឹត្ត បានបញ្ជារអោយប្រព្រឹត្ត នូវអំពើរំលោភបំពានធ្ងន់ធ្ងរណាមួយ នៃអនុសញ្ញាបច្ចុប្បន្ននេះដែលមានកំណត់នៅក្នុងមាត្រាដូចតទៅនេះ"។

៧. ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណី ភ័ន្តច្រលំពីភាពខុសផ្លែកគ្នារវាងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាជារដ្ឋភាគីនៃអនុសញ្ញាមួយ និងអនុភាពក្នុងប្រទេសផ្ទៃក្នុងរបស់អនុសញ្ញាមួយនោះ ទើបដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាមានការចាំបាច់ក្នុងការអះអាងថាអនុសញ្ញាទាំងនោះ មិនត្រូវបានផ្តោលទោសឡើយ[15] ។ វាមិនចាំបាច់ត្រូវឆ្លើយតបនឹងទឡ្ហីករណ៍នេះឡើយ ព្រោះមេធាវីការពារក្តីមិនបានលើកឡើងថាប្រទេសកម្ពុជា បានផ្តោលទោសចំពោះអនុសញ្ញាទាំងនោះទេ ហើយការផ្តោលទោសបែបនេះ នឹងប៉ះពាល់ដល់កតាព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងនាមជារដ្ឋមួយ ។

**២. ដើមបណ្តឹងរដ្ឋប្បវេណី ភ័ន្តច្រលំពីទឡ្ហីករណ៍របស់មេធាវីការពារក្តីទាក់ទងទៅនឹងការបន្តវេនរបស់រដ្ឋចំពោះអនុសញ្ញានានា**

៨. មេធាវីការពារក្តីបានយល់ច្រលំពីបញ្ហានៃការបន្តវេនរបស់រដ្ឋចំពោះអនុសញ្ញានានា។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថាដោយសារតែអនុសញ្ញាទាំងនេះ "បានចូលជាធរមានមុនរបបកម្ពុជាប្រជាធិបតេយ្យ" ការបន្តវេនកាន់អំណាចរបស់រដ្ឋាភិបាល មិនប៉ះពាល់ដល់ការអនុវត្តរបស់ពួកគេឡើយ។ ដូចដែលលោក Shaw បានលើកឡើងថា បញ្ហានៃការបន្តវេនរបស់រដ្ឋមួយ ត្រូវតែចែកឲ្យដាច់ស្រលះពីបញ្ហានៃការបន្តវេនរបស់រដ្ឋាភិបាល ជាពិសេសជាពិសេសការបន្តវេនដែលកើតចេញពីការធ្វើបដិវត្តន៍។ ដូច្នេះ ការឡើងកាន់កាប់អំណាចរបស់ពួកខ្មែរក្រហម មិនបានប៉ះពាល់ដល់ការរក្សាអនុសញ្ញាដែលចូលជាធរមានទាំងនោះទេ...[16]។ មេធាវីការពារក្តីមិនបានលើកឡើងថាបញ្ហានៃការបន្តវេនពីរដ្ឋមួយទៅរដ្ឋមួយ បានកើតឡើងទាក់ទងនឹងអនុសញ្ញាទីក្រុងហ្សឺណែវឡើយ[17] ផ្ទុយទៅវិញមេធាវីការពារក្តី គ្រាន់តែ

---

[15] ចម្លើយតប, កថាខណ្ឌទី១០។

[16] ដូចជើងទំព័រខាងលើ។

[17] ដោយសារតែមេធាវីការពារក្តី មិនបានលើកឡើងថាបញ្ហានៃការបន្តវេនរបស់រដ្ឋមួយ បានកើតឡើងទាក់ទងនឹងសិទ្ធិសញ្ញាទីក្រុងហ្សឺណែវទេនោះ វាមិនចាំបាច់ក្នុងគិតពិចារណាពីទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ប៉ុន្តែមេធាវីការពារក្តី កត់សម្គាល់ថាការដកស្រង់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបង្ហាញយ៉ាងច្បាស់ថាកាតព្វកិច្ចដែលកើតចេញពីសិទ្ធិសញ្ញាទីក្រុងហ្សឺណែវ គឺជាកាតព្វកិច្ចរបស់រដ្ឋ មិនមែនជាកាតព្វកិច្ចរបស់បុគ្គលឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដកស្រង់ពីអត្ថបទរបស់សាស្ត្រាចារ្យ Cassese ថា "ការផ្តន្ទាទោសគឺលែងផ្ទុកផ្តាក់ទៅអោយឆន្ទៈល្អរបស់រដ្ឋទៀតហើយ។ វាជាគឺជាកាតព្វកិច្ចមួយដែលដាក់បន្ទុកមកលើរដ្ឋទាំងនោះ។" ចម្លើយតប កថាខណ្ឌ ១២ (គូសបញ្ជាក់បន្ថែម)។

បានលើកឡើងថាបញ្ហានេះទាក់ទងទៅនឹងអនុសញ្ញាប្រល័យពូជសាសន៍តែប៉ុណ្ណោះ[18] ។ មេធាវីការពារក្តី មិនបានលើកឡើងថាបញ្ហានេះបានកើតឡើងដោយសារតែការឡើងកាន់អំណាចរបស់ពួកខ្មែរក្រហមនោះទេ ប៉ុន្តែដោយសារតែប្រទេសកម្ពុជាបានក្លាយជារដ្ឋភាគីនៃអនុសញ្ញាប្រល័យពូជសាសន៍មុនពេលទទួលបានឯករាជ្យពីប្រទេសបារាំង។

៩. គោលការណ៍ "រដ្ឋស្អាតស្អំ" សំដៅលើការពិតដែលថារដ្ឋដែលទើបតែទទួលបានឯករាជ្យថ្មីថ្មោង មិនអាចក្លាយជាភាគីនៃអនុសញ្ញាមួយដោយគ្រាន់តែមានហេតុផលថាអនុសញ្ញានោះបានចូលជាធរមានមុនការបរិច្ឆេទនៃការនបន្តវេននោះទេ[19]។ ដូច្នេះការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថាខ្មែរក្រហមមិនបានអនុវត្តគោលនយោបាយរដ្ឋស្អាតស្អំ[20] មិនចាំបាច់ត្រូវដោះស្រាយឡើយ។ បញ្ហាគឺមិនស្ថិតនៅត្រង់ថាតើខ្មែរក្រហមបានអនុវត្តគោលនយោស្អាតស្អំដែរឬអត់ទេ ប៉ុន្តែវានៅត្រង់ថាតើប្រទេសកម្ពុជានៅតែត្រូវចងដោយអនុសញ្ញាមួយដែលក្នុងនោះខ្លួនបានក្លាយជាភាគីមុនក្លាយជារដ្ឋឯករាជ្យមួយដែរឬយ៉ាណា។ ក្នុងករណីណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីពិតជាភ័ន្តច្រលំក្នុងការសន្និដ្ឋានថាសំណើរបស់ខ្មែរក្រហមក្នុងការអនុវត្តវិធានអន្តរជាតិ មានតម្លៃស្មើនឹងកិច្ចព្រមព្រៀងដែលចងដោយអនុសញ្ញាប្រល័យពូជសាសន៍ ។

### គ. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រលំក្នុងការសន្និដ្ឋានថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវតែយកមកអនុវត្តដោយផ្ទាល់នៅ អវតក

១០. ដើមបណ្តឹរដ្ឋប្បវេណី យល់ឃើញថា "ជនត្រូវចោទនីមួយៗ បានលើកឡើងថាច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនអាចត្រូវបានគេយកមកអនុវត្តដោយផ្ទាល់ក្រោមច្បាប់កម្ពុជាបានទេ ដូច្នេះមិនអាចយកជាមូលដ្ឋានសម្រាប់នីតិវិធីព្រហ្មទណ្ឌបានឡើយ ជាពិសេសនៅពេលដែលឧក្រិដ្ឋនោះបានកើត

---

[18] សូមមើលបណ្តឹងឧទ្ធរណ៍, កថាខណ្ឌទី១១៧។

[19] អត្ថបទរបស់ SHAW ទំព័រ ៣០៨-៣០៩។ វិធានទូទៅនេះត្រូវបានចងក្រងទៅជាច្បាប់នៅក្នុងមាត្រា ៦ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីការបន្តវេនរបស់រដ្ឋនានា ទាក់ទងទៅនឹងសន្ធិសញ្ញា ដែលបានចូលជាធរមាននៅថ្ងៃទី ៦ វិច្ឆិកា ១៩៩៦ ។ អង្គការសហប្រជាជាតិ *Treaty Series*, vol. 1946.

[20] ចម្លើយតប, កថាខណ្ឌទី១១។

ឡើង ការហាមឃាត់មិនទាន់ក្លាយជាបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឡើយទេ[21]" មេធាវីការពារក្តី មិនបានលើកឡើងថា អំពើប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិសញ្ញាទីក្រុងហ្សឺណែវ មិនមែនជាបទឧក្រិដ្ឋក្រោមច្បាប់ ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់១៩៧៩ ឡើយ។ មេធាវីការពារក្តី គ្រាន់តែបានលើកឡើងថាអំពើពាក់ព័ន្ធមួយ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីឆ្នាំ១៩៧៥ ដល់១៩៧៩ឡើយ[22]។

១១. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្កើតទឡ្ហីករណ៍ណាមួយដើម្បីគាំទ្រគោលជំហររបស់ពួកគេដែលថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចយកមកអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជាឡើយ ក្រៅតែពីបានធ្វើការកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងក្នុងករណី ឌុច បានអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់[23]។ ក្នុងន័យនេះ បញ្ហាទាក់ទងទៅនឹងសាលដីការបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ឌុច ត្រូវបានយកមកពិភាក្សាដូចខាងលើ។

១២. ដើមបណ្តឹងរដ្ឋប្បវេណី យល់ច្រលំពីទំនាក់ទំនងនៃលក្ខន្តិកៈនៃគោលការណ៍ត្រូវតែអនុវត្ត (jus cogens)។ ដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថាសារជាតិនៃបទដ្ឋានទាំងនេះ គឺស្ថិតនៅលើការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ erga omnes។ វាមិនមែនគ្រាន់តែជាបញ្ហានៃគោលជំហរដែលមានឯកសិទ្ធិប៉ុណ្ណោះទេ ប៉ុន្តែវាក៏តម្រូវមានកតាព្វកិច្ចដែលជំនួសសញ្ញាណនៃអធិបតេយ្យភាពរបស់រដ្ឋមួយផងដែរ[24]។ គ្មានសិទ្ធិអំណាចណាមួយត្រូវបានផ្តល់ឲ្យចំពោះការអះអាងបែបនេះទេ។ សារជាតិនៃគោលការណ៍ត្រូវតែអនុវត្ត ធ្វើឲ្យរដ្ឋមានកតាព្វកិច្ច[25] ប៉ុន្តែមិននាំឲ្យមានការទទួលខុសត្រូវ

---

[21] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៣។

[22] សូមមើលបណ្តឹងសារទុក្ខ, កថាខណ្ឌទី២០០ ដល់២៣១។

[23] ចម្លើយតប, កថាខណ្ឌទី១៥ ដល់១៦។

[24] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៧។

[25] អត្ថបទរបស់ MALCOLM N. SHAW មានចំណងជា ច្បាប់អន្តរជាតិ ទំព័រ 390 (Cambridge University Press, 2008 6th ed) "បន្ថែមពីនេះ សន្ធិសញ្ញាពិសេសមួយចំនួនទៀតអាចបង្កើតអោយមានកាតព្វកិច្ច ឬសិទ្ធិ erga omnes ហើយនៅក្នុងករណីបែបនេះ គ្រប់រដ្ឋទាំងអស់ នឹងត្រូវសន្មតថាត្រូវបានចងភ្ជាប់ដោយអនុសញ្ញាទាំងនេះ ហើយនឹងទទួលអត្ថប្រយោជន៍ផងដែរ" (គូសបញ្ជាក់បន្ថែម)។

ជាលក្ខណៈបុគ្គលដោយផ្ទាល់ឡើយ។ ជាងនេះទៅទៀត នៅពេលដែលវាមិនដាក់កំហិតកតាព្វកិច្ចលើរដ្ឋមិនឲ្យពាក់ព័ន្ធក្នុងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការរំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសញ្ញាទីក្រុងហ្សឺណែវ កាតព្វកិច្ចក្នុងការកាត់ទោសឧក្រិដ្ឋកម្មបែបនេះ មិនត្រូវបានដោះស្រាយឡើយ[26]។

**ឃ. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រលំក្នុងការសន្និដ្ឋានថាគោលការណ៍នីត្យានុកូលភាព មិនអាចទប់ស្កាត់ការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិបានឡើយ**

**១. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រំក្នុងការវិភាគរបស់ពួកគេទៅលើការអនុវត្តមាត្រា ១៥ (២) កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ**

១៣. ដើមបណ្តឹងរដ្ឋប្បវេណីហាក់បីដូចជាយល់ច្រឡំ ឬមិនយកចិត្តទុកដាក់ចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថាគោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់កម្ពុជា មានលក្ខណៈតឹងរឹងជាងគោលការណ៍នីត្យានុកូលភាពនៅកម្រិតអន្តរជាតិ។ ពួកគេពិតជាបានធ្វើការកត់សម្គាល់ថា មេធាវីការពារក្តីបានប្រកាន់យកគោលជំហរដែលថាគោលការនីត្យានុកូលភាពដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មានលក្ខណៈតឹងរឹងជាងគោលការណ៍នីត្យានុកូលភាពដែលមានចែងនៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[27] ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី ខកខានមិនបានពន្យល់ថាតើហេតុអ្វីបានជាពួកគេមិនយល់ឃើញដូចមេធាវីការពារក្តី ។ ពួកគេគ្រាន់តែអះអាងថា មាត្រា១៥ (២)

---

[26] អត្ថបទរបស់ WARD N. FERDINANDUSSE មានចំណងជើងថា ការអនុវត្តដោយផ្ទាល់នូវច្បាប់ព្រហ្មទណ្ឌអន្តរជាតិទៅក្នុងតុលាការជាតិ (DIRECT APPLICATION OF INTERNATIONAL CRIMINAL LAW IN NATIONAL COURTS) ទំព័រ ១៨២-១៨៥ (T.M.C. Asser Press 2006)។ សូមមើលផងដែរ អត្ថបទរបស់ Michael Scharf ចេញពីសំនុំឯកសារនីរទេស៖ និក្ខេបបទស្តីពីការយកយុត្តិធម៌មកដូរដូរដើម្បីសន្តិភាព *(From the Exile Files: an Essay on Trading Justice for Peac)* 63 WASH. & LEE L. REV. 339, 364-367 (2006) ពិភាក្សាអំពីចរិតលក្ខណៈ *jus cogens* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងកាតព្វកិច្ចរបស់រដ្ឋមួយ។ "ថ្វីបើមិនមានចំណោទដែលថា សហគមន៍អន្តរជាតិបានទទួលយកថា ការហាមឃាត់ប្រឆាំងនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានឋានៈជាវិធាន jus cogens ក៏ដោយ រឿងនេះមិនមានន័យថា កាតព្វកិច្ចជាប់ពាក់ព័ន្ធដើម្បីផ្តន្ទាទោសទទួលបានឋានៈដោយស្មើគ្នានោះឡើយ។ តាមពិត មានគ្រប់ភស្តុតាងទាំងអស់ដែលបង្ហាញផ្ទុយពីនេះ"។

[27] ចម្លើយតប, កថាខណ្ឌទី១៥ ដល់១៨។

នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ អនុញ្ញាតិឲ្យមានការកាត់សេចក្តី និងការដាក់ទណ្ឌកម្មចំពោះអ្នកដែលបានរំលោភគោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ដោយមិនគិតពីប្រភេទបទឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ[28]។ នេះជាការពិត ប៉ុន្តែវាមិនបានផ្លាស់ប្តូរការពិតដែលថាគោលការណ៍នីត្យានុកូលភាពក្នុងច្បាប់ជាតិ គឺមានលក្ខណៈតឹងរឹងជាង។ ដូចដែលបានចែងយ៉ាងច្បាស់ក្នុងមាត្រា ៥(២) នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ វាមិនមានការដាក់កំហិតលើ ឬមិនមានបដិប្បញ្ញាតិពីសិទ្ធិមនុស្សជាសារវន្តណាមួយដែលទទួលស្គាល់ ឬចូលជាធរមានក្នុងរដ្ឋជាភាគីនៃអនុសញ្ញាបច្ចុប្បន្ននេះ ដោយអនុលោមតាមច្បាប់ សិទ្ធិសញ្ញា បទប្បញ្ញាតិ ឬទំនៀមទម្លាប់ ដោយឈរលើលេសដោះសារដែលថាកតិកាសញ្ញានៅពេលបច្ចុប្បន្ននេះ មិនបានទទួលស្គាល់សិទ្ធិបែបនេះ ឬក៏ថាវាទទួលស្គាល់ដែរប៉ុន្តែក្នុងកម្រិតមួយដែលតិចជាងមុន។

១៤. ដើមបណ្តឹងរដ្ឋប្បវេណីស្រង់យកជាសំអាងនូវសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* ដែលបានគូសបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែកំណត់ថាតើបទល្មើស និងទម្រង់នៃការចូលរួម ដែលបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយដែលបានធ្វើវិសោធនកម្ម ត្រូវបានទទួលស្គាល់ក្រោមច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[29]។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងថា "ការប្រើ ឆ្នាប់ "ឬ" និងមិនប្រើឆ្នាប់ "និង" បានបញ្ជាក់ថាអត្ថិភាពនៃឧក្រិដ្ឋកម្មបែបក្រោមច្បាប់អន្តរជាតិ ក៏ដូចជាបទឧក្រិដ្ឋមួយដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះ គឺមានលក្ខណៈគ្រប់គ្រាន់ដោយខ្លួនឯងដើម្បីអនុញ្ញាតិឲ្យមានការប្រកាសសាលក្រម[30]"។ ដូចដែលបានពន្យល់ខាងលើ គេមិនបានផ្តល់ទម្ងន់ទៅលើសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* ទៅលើចំណុចនេះឡើយ។ សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *ឌុច* មិនត្រូវបានគេស្នើសុំអោយពិចារណាទៅលើ គោលការណ៍នីត្យានុកូលភាពក្រោមច្បាប់ជាតិឡើយ ហើយគ្មានអ្វីនៅក្នុងសាលក្រមនេះ ដែលនាំអោយមានការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់អំណាចដែលខ្លួនមានស្រាប់ ដោយការផ្តួចផ្តើមខ្លួនឯង (*proprio motu*) ឬ ដោយ (*sua*

---

[28] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៩។

[29] គូសបញ្ជាក់បន្ថែមដោយដើមបណ្តឹងរដ្ឋប្បវេណី។

[30] ចម្លើយតប, កថាខណ្ឌទី២១។

*sponte*) ដើម្បីធ្វើដូច្នោះឡើយ។ ដូចដែលបានកត់សម្គាល់ ឌុច បានសារភាពនៅមុនការជំនុំជម្រះក្តី ហើយ មេធាវីការពារក្តី *ឌុច* បានលើកឡើងពីការតតាំងនឹងបញ្ហាយុត្តាធិការយ៉ាងតិចតួចបំផុត តតាំងទៅលើច្បាប់ដែលយកមកអនុវត្ត និងទម្រង់នៃការទទួលខុសត្រូវ។

**២. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រលំដោយសន្និដ្ឋានថាគោលការណ៍នីត្យានុកូលភាពមិនត្រូវបានរំលោភបំពាន**

១៥. ដើមបណ្តឹងរដ្ឋប្បវេណី បន្តលើកទឡ្ហីករណ៍ពីរទៀតដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនថា គោល-ការណ៍នីត្យានុកូលភាព មិនត្រូវបានរំលោភបំពាន។ ទីមួយដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា គោលការណ៍នីត្យានុកូលភាព មិនត្រូវបានរំលោភបំពានដោយហេតុថា "អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញរួចមកហើយថា "បញ្ហាដែលថា អវតក ត្រូវបានបង្កើតឡើង និងបានបញ្ជាក់យុត្តាធិការទៅលើបទល្មើសនានាបន្ទាប់ពីបទល្មើសទាំងនោះត្រូវបានគេចោទថា ត្រូវបានប្រព្រឹត្តមិនបានរំលោភបំពានលើ គោលការណ៍នីត្យានុកូលភាពឡើយ""[31]។ បញ្ហាដែលថា អវតក ត្រូវបានបង្កើតឡើងបន្ទាប់ពីមានការប្រព្រឹត្តបទល្មើសគឺមិនមែនជាបញ្ហាចោទឡើយ។ គោលការណ៍នីត្យានុកូលភាព គឺមិនបានរំលោភបំពាន ដោយការណ៍ដែលថា អវតក ត្រូវបានបង្កើតឡើង និងបានបញ្ជាក់ពីយុត្តាធិការបន្ទាប់ពីបទល្មើសត្រូវបានគេចោទថាបានកើតមានឡើងឡើយ។ គោលការណ៍នីត្យានុកូលភាព ត្រូវបានរំលោភបំពានព្រោះថា បទល្មើសដែលបច្ចុប្បន្នកំពុងត្រូវបានគេចោទប្រកាន់ <u>មិនទាន់ក្លាយជាបទល្មើសព្រហ្មទណ្ឌនៅកម្ពុជា</u> ក្នុងអំឡុងពេលពាក់ព័ន្ធនោះឡើយ។

១៦. ទីពីរ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ច្បាប់បង្កើត អវតក មិនមែនជាការបង្កើតច្បាប់ថ្មីទេ ប៉ុន្តែគ្រាន់តែ "ប្រែក្លាយនូវអនុសញ្ញា និងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលនៅជាធរមាននាអំឡុងពេលនៃសម័យកម្ពុជាប្រជាធិបតេយ្យ មកជាច្បាប់ជាតិកម្ពុជាប៉ុណ្ណោះ"[32]។ ដើមបណ្តឹងរដ្ឋប្បវេណី យក

---

[31] ដូចដើងទំព័រខាងលើ កថាខណ្ឌ ២៣ *ដោយយកស្រង់នូវ រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អសជសាលក្រម ចុះថ្ងៃទី ២៦ កក្កដា ២០១០ ឯកសារលេខ E188 កថាខណ្ឌ ៣៤។

[32] ចម្លើយតប កថាខណ្ឌ ២៣។

ជាសំអាងនូវអត្ថបទមួយរបស់ David Boyle ដើម្បីគាំទ្រដល់ការអះអាងនេះ[33]។ ដើមបណ្តឹងរដ្ឋប្បវេណីខកខានមិនបានទទួលស្គាល់ថា "ការប្រែក្លាយ" នេះនឹងបង្កើតនូវច្បាប់ជាតិកម្ពុជាថ្មីឡើយ។ សូមពិចារណាទៅវិញថាចុះបើ អវតក ព្យាយាម "កែប្រែ" នូវច្បាប់ព្រហ្មទណ្ឌជាតិមួយចំណែករបស់សហរដ្ឋអាមេរិចមកជាច្បាប់ជាតិកម្ពុជាវិញតើយ៉ាងម៉េច។ នេះគឺមិនមែនជាបញ្ហានីតិវិធីឡើយ។ ការវិភាគនេះមិនប្រែប្រួលឡើយ នៅពេលដែលច្បាប់មួយដែលគេព្យាយាមយកមកប្រើគឺជាច្បាប់អន្តរជាតិដែលមិនមែនមកពីយុត្តាធិការបរទេសដទៃទៀតក៏ដោយ។

១៧. ដើមបណ្តឹងរដ្ឋប្បវេណី យកជាសំអាងយុត្តិសាស្ត្រអន្តរជាតិដែលបានពិចារណា "បញ្ហាដែលថា តើអានុភាពប្រតិសកម្មនៃវិធានយុត្តាធិការ ទាក់ទងនឹងបទល្មើសអន្តរជាតិរំលោភបំពានសិទ្ធិមនុស្ស..."[34]។ ដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY ក្នុងរឿងក្តី *Delalić* ដែល "យល់ឃើញថា ច្បាប់លក្ខន្តិកៈរបស់ខ្លួន "មិនបង្កើតនូវច្បាប់សារធាតុឡើយ ប៉ុន្តែបង្កើតជាអំណាចរបស់តុលាការមួយ និងបរិបទសម្រាប់ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ""[35]។ នេះធ្វើអោយច្រលំទៅលើបញ្ហាដែលចោទឡើង ព្រោះថា អវតក មិនមែនជាតុលាការអន្តរជាតិដែលអាចងាយស្រួលសម្រេចថា តើតុលាការនេះមានយុត្តាធិការទៅលើបទល្មើសមួយចំនួនដែលបានក្លាយជាបទល្មើសព្រហ្មទណ្ឌរួចទៅហើយនៅក្នុងច្បាប់អន្តរជាតិនោះទេ។ ដើម្បីប្រើប្រាស់នូវបទល្មើសអន្តរជាតិ ដោយមិនអោយរំលោភបំពានលើ គោលការណ៍នីត្យានុកូលភាព ដែលទទួលស្គាល់ដោយច្បាប់កម្ពុជានោះ[36] អវតក ត្រូវតែរកអោយឃើញថាបទល្មើសទាំងនេះបានក្លាយជាបទល្មើសព្រហ្មទណ្ឌនៅកម្ពុជា នៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

**ង. ដើមបណ្តឹងរដ្ឋប្បវេណីភ័ន្តច្រលំក្នុងការវិភាគរបស់ខ្លួនទៅលើការអាចប្រមើលមើលឃើញជាមុន និងការផ្សព្វផ្សាយដែលអាចស្វែងរកបាន**

---

[33] ដូចជើងទំព័រខាងលើ កំណត់សំគាល់ ៣៥។

[34] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៤។

[35] ដូចជើងទំព័រខាងលើ ។.

[36] សូមមើលក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ៦។

១៨. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ចរិតលក្ខណៈឃោរឃៅនៃបទល្មើសអន្តរជាតិត្រូវតែបានគេយកមកពិចារណា នៅពេលសម្រេចថាតើការទទួលខុសត្រូវព្រហ្មទណ្ឌអាចប្រមើលមើលឃើញជាមុនដោយជនត្រូវចោទ ឬជនជាប់ចោទដែរឬទេ[37]។ មេធាវីការពារក្តីមិនជំទាស់ទៅនឹងអ្វីដែលថាចរិតលក្ខណៈឃោរឃៅនៃបទល្មើស ត្រូវបានពិចារណាថាជាកត្តាមួយដើម្បីកំណត់អំពីភាពអាចប្រមើលមើលឃើញជាមុនឡើយ។ ប៉ុន្តែ "ភាពអសីលធម៌ ឬ លក្ខណៈឃោរឃៅនៃទង្វើមួយមិនជាកត្តាគ្រប់គ្រាន់ដើម្បីធានាអោយទង្វើនោះក្លាយជាបទល្មើសព្រហ្មទណ្ឌ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ"[38]។

១៩. ដើមបណ្តឹងរដ្ឋប្បវេណីក៏អះអាងផងដែរថា ការទទួលខុសត្រូវ ត្រូវតែអាចប្រមើលមើលឃើញជាមុនដោយលោក អៀង សារី សំអាងលើឋានៈតួនាទីរបស់គាត់ជាមេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ[39]។ ឋានៈតួនាទីរបស់លោក អៀង សារី ជាមេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យមិនឈានដល់ការសន្និដ្ឋានថាគាត់គួរតែអាចប្រមើលមើលឃើញជាមុន នូវការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមិននៅជាធរមាននៅក្នុងច្បាប់កម្ពុជានាអំឡុងពេលពាក់ព័ន្ធឡើយ។ ការទទួលខុសត្រូវព្រហ្មទណ្ឌនឹងមិនអាចប្រមើលមើលឃើញជាមុន ជាពិសេស វាជាការពិតនៅពេលដែលពិចារណាដល់ឋានៈតួនាទីជាអ្នកដឹកនាំរបស់គាត់។ វាប្រហែលជាអាចទៅរួចបើសិនជាជនជាប់ចោទប្រព្រឹត្តដោយផ្ទាល់នូវអំពើមួយដែល មានលក្ខណៈជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើបំពារបំពានធ្ងន់ធ្ងរ ជននោះអាចប្រមើលមើលឃើញជាមុនថាទង្វើបែបនោះគឺជាបទល្មើស។ ប៉ុន្តែ នៅពេលមានការជាប់ពាក់ព័ន្ធជាមួយទម្រង់នៃការទទួលខុសត្រូវដូចជា សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ វាមានលំបាកក្រៃលែងដើម្បីសន្មតថាការទទួលខុសត្រូវគឺ អាចប្រមើលមើលឃើញជាមុនបាននោះ។

---

[37] ចម្លើយតប កថាខណ្ឌ ២៩-៣២។

[38] រឿងក្តី រដ្ឋអាជ្ញា តទល់នឹង *Milutinović et al* សំណុំរឿង IT-99-37-AR72 សេចក្តីសម្រេចលើពាក្យសុំរបស់ Dragoljub Ojdanić តតាំងនឹងបញ្ញាយុត្តាធិការស្តីពី សហឧក្រិដ្ឋកម្មរួម អង្គជំនុំជម្រះតុលាការកំពូល ICTY ចុះថ្ងៃទី ២១ ឧសភា ២០០៣ កថាខណ្ឌ ៤២។

[39] ចម្លើយតប កថាខណ្ឌ ៣៣-៣៩។

ប្រហែលជាគ្មានទស្សនាទានណា ដែលលាតសន្ធឹងនូវទ្រឹស្តីនៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ខ្លាំងក្លាដូចជាការទទួលខុសត្រូវរបស់ថ្នាក់លើ ឬមេបញ្ជាការ ចំពោះការប្រព្រឹត្តបទល្មើសដោយអ្នកក្រោមបង្គាប់ឡើយ។ ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺជាការទទួលខុសត្រូវបែបអកម្ម ដែលក្នុងនោះជនល្មើសត្រូវផ្តន្ទាទោសចំពោះការ *មិនធ្វើអំពើ*។ ប៉ុន្តែវាលាតសន្ធឹងលើសពីនេះខ្លាំងថែមទៀត។ ថ្នាក់លើត្រូវដាក់អោយទទួលខុសត្រូវ ចំពោះបទល្មើសជាក់លាក់មួយ មិនមែនដោយសារតែអំពើរបស់គាត់ ចូលទៅក្នុងនិយមន័យនៃបទល្មើសនោះទេ ប៉ុន្តែគឺដោយសារគាត់ខកខានមិនបានរារាំង ចំពោះការប្រព្រឹត្តអំពើនោះដោយអ្នកដទៃទៀត។ អ្វីដែលសំខាន់នោះគឺថា ថ្នាក់លើត្រូវដាក់អោយទទួលខុសត្រូវចំពោះ *បទល្មើសពិតប្រាកដ* របស់អ្នកនៅក្រោមបង្គាប់ មិនមែនចំពោះបទល្មើសដោយឡែកដែលផ្តោតទៅលើការធ្វេសប្រហែសក្នុងតួនាទីរបស់មេបញ្ជាការឡើយ[40]។

២០. ហេតុដូច្នេះវាមិនគ្រប់គ្រាន់ក្នុងការថ្លែងថា ការទទួលខុសត្រូវព្រហ្មទណ្ឌគួរ អាចប្រមើលមើលឃើញជាមុនបាន ដោយសំអាងទៅលើចរិតលក្ខណៈនៃបទល្មើសដែលចោទប្រកាន់ ឬដោយសារឋានៈតួនាទីនៃការទទួលខុសត្រូវប្រឆាំងនឹងលោក អៀង សារី ឡើយ។ អង្គបុរេជំនុំជម្រះគួរបន្តនូវការអនុវត្តពីមុនរបស់ខ្លួនក្នុងការសម្រេចថា តើជនជាប់ចោទពិតជាអាចប្រមើលមើលឃើញជាមុនបាននូវការទទួលខុសត្រូវដែរឬអត់ ជាជាគ្រាន់តែស្រាវជ្រាវរកថា តើការទទួលខុសត្រូវពិតជានៅជាធរមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ[41]។

---

[40] អត្ថបទរបស់ David L. Nersessian ក្រោមចំណងជើងថា៖ *អុញ ខ្ញុំបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍! ភាពខុសប្រក្រតីនៃការទទួលខុសត្រូវដោយសន្មតចំពោះបទល្មើសអន្តរជាតិធ្ងន់ធ្ងរ* ។ 30 FLETCHER F. WORLD AFF. 81, 88-89 (2006).។

[41] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពី សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ២០ ឧសភា ២០១០ ឯកសារលេខ D97/14/15, ERN: 00486521-00486589កថាខណ្ឌ៤៥។

សូមអង្គបុរេជំនុំជម្រះមេត្តាទទួលនូវការគោរពដ៏ស្មោះត្រង់អំពីយើងខ្ញុំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១១

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី